អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

Kampuchea Action to Promote Education (KAPE)

# ឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនមានដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះឈ្មោះក្រុមហ៊ុន ឬអាជីវកម្ម ក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- បណ្ណប៉ាតង់ប្រចាំឆ្នាំ២០២៥ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- វិញ្ញាបនបត្រប្រកបអាជីវកម្ម ចេញដោយក្រសួងពាក់ព័ន្ធ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ក្នុងការងាររបស់ខ្លួន ០១ ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់

ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើចូលដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម មានសម្ព័ន្ធភាពជាមួយគ្នា ឬប្រភពតែមួយ គឺមិនត្រូវបានអនុញ្ញាត និងបដិសេធដោយស្វ័យប្រវត្តិ។

<u>បញ្ជាក់៖</u>

- ក្រោយពីការប្រជុំតម្រង់ទិសរួច ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ទាំងអស់ ត្រូវរៀបចំឯកសារដេញថ្លៃដែលបានបំពេញរួច ប្រគល់ជូនផ្នែករដ្ឋបាល ការិយាល័យរង (សាលារៀនជំនាន់ថ្មី) អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ស្ថិតនៅក្នុងបរិវេណ វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ។
- ការប្រជុំបើកកញ្ចប់ឯកសារដេញថ្លៃនឹងប្រព្រឹត្តិទៅដោយផ្ទាល់នៅសាលប្រជុំរបស់វិទ្យាល័យព្រះស៊ីសុវត្ថិរាជធានីភ្នំពេញ (សាលារៀនជំនាន់ថ្មី) ចំណែកកាលបរិច្ឆេទនៃការបើកកញ្ចប់ឯកសារដេញថ្លៃសូមជូនដំណឹងពេលក្រោយ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ នឹងត្រូវចែកជូនតែក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ដែលបានមកចូលរួមប្រជុំតម្រង់ទិសតែប៉ុណ្ណោះ។
- អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងមិនទទួលខុសត្រូវក្នុងការបើកកញ្ចប់ដេញថ្លៃទេ ប្រសិនគ្រប់ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ណាមួយដែលអវត្តមានមិនបានអញ្ជើញមកចូលរួមស្តាប់ការណែនាំ និងការតម្រង់ទិសជំនួយស្មារតីនៃការចូលរួមដេញថ្លៃ មានដូចជា៖ (គំរូប្លង់ រូបភាព ទីតាំងសាលារៀន និងផ្សេងទៀត)។
- រាល់ឯកសារសម្រង់តម្លៃ (ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម១០%) ប្រសិនបើមានការបញ្ចុះតម្លៃ ត្រូវបញ្ចុះឱ្យរួចជាស្រេចមុនការបើកកញ្ចប់ដេញថ្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ត្រូវប្រេកក្នុងស្រោមបិទផ្និត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យរង (សាលារៀនជំនាន់ថ្មី) ផ្នែករដ្ឋបាល នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ស្ថិតនៅក្នុងបរិវេណ

វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ ហើយហាមដាច់ខាតមិនអនុញ្ញាតឱ្យដាក់ផ្ញើមកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល តេឡេក្រាម WhatsApp........) ឡើយ។

- គ្រប់ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ទាំងអស់ អាចចូលរួមដេញថ្លៃបានលុះត្រាតែក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម នោះបានចុះទៅសិក្សាមើលទីតាំងសាលារៀនគោលដៅដោយផ្ទាល់ និងប្រៀបធៀបជាមួយ BoQ ដែលបានផ្តល់ដោយគម្រោង ហើយមានការចុះហត្ថលេខា បោះត្រាទទួលស្គាល់ពីនាយកសាលារៀនគោលដៅថាពិតជាបានចុះពិនិត្យមើលត្រឹមត្រូវពិតប្រាកដមែន (ការចុះពិនិត្យការងារត្រូវធ្វើ មិនមែនចុះទៅបោះត្រានាយកសាលារៀនទេ) និងដាក់នៅក្នុងស្រោមសំបុត្រដោយឡែកពីពាក្យសុំចូលរួមដេញថ្លៃ ដើម្បីងាយស្រួលគណៈកម្មការលទ្ធកម្មត្រួតពិនិត្យមុននឹងបើកកញ្ចប់ដេញថ្លៃ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ដែលមិនបានដាក់ជូនមកផ្នែករដ្ឋបាល ការិយាល័យរង (សាលារៀនជំនាន់ថ្មី) របស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាមោឃៈ។
- អ្នកបានដាក់ពាក្យដេញថ្លៃទាំងអស់ ត្រូវតែអញ្ជើញមកចូលរួមប្រជុំស្តាប់ការបើកកញ្ចប់ដេញថ្លៃឱ្យបានទាន់ពេលវេលាកំណត់ ប្រសិនបើករណីអ្នកដេញថ្លៃណាមួយដែលមិនបានមកចូលរួមប្រជុំបើកកញ្ចប់ដេញថ្លៃតាមពេលវេលាកំណត់ទេ ឬក៏អវត្តមានក្នុង (រយៈពេល១៥នាទី) ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុនសំណង់ ម្ចាស់អ្នកម៉ៅការសំណង់ និងម្ចាស់សហគ្រាស សិប្បកម្ម ។
- យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទនៃការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើមានករណីចាំបាច់ ហើយយើងខ្ញុំនឹងធ្វើសេចក្តីជូនដំណឹងជាមុនទៅក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ដែលបានផ្ញើឯកសារដេញថ្លៃទៅតាមអសយដ្ឋាននៅក្នុងបញ្ជីចុងក្រោយ។
- រាល់ឯកសារដែលដាក់មកហើយ គណៈកម្មការយើងខ្ញុំនឹងមិនប្រគល់ជូនត្រឡប់ទៅវិញឡើយ។